ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១២០ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការរៀបចំនិងការប្រព្រឹត្តទៅនៃអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើត **អនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត** សរសេរអក្សរកាត់ **អ.គ.វ.ខ.** ជាសេនាធិការឱ្យរដ្ឋបាលរាជធានី ខេត្ត ដើម្បីជាយន្តការក្នុងការពិនិត្យសម្រេចលើការវិនិយោគឯកជន និងការដោះស្រាយវិវាទពាក់ព័ន្ធនឹងគម្រោងវិនិយោគ។

## ជំពូកទី២
## សមាសភាព

**មាត្រា២.-**

**អ.គ.វ. វ.ខ.** មានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- | អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត | ប្រធាន |
| ២- | អភិបាលរងនៃគណៈអភិបាលរាជធានី ខេត្ត ១រូប | អនុប្រធាន |
| ៣- | នាយករដ្ឋបាលនៃរដ្ឋបាលរាជធានី ខេត្ត | សមាជិក |
| ៤- | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥- | ប្រធានមន្ទីរពាណិជ្ជកម្ម | សមាជិក |
| ៦- | ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិក |
| ៧- | ប្រធានមន្ទីររ៉ែ និងថាមពល | សមាជិក |
| ៨- | ប្រធានមន្ទីរសុខាភិបាល | សមាជិក |
| ៩- | ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១០- | ប្រធានមន្ទីរបរិស្ថាន | សមាជិក |
| ១១- | ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី | សមាជិក |
| ១២- | ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១៣- | ប្រធានមន្ទីរផែនការ | សមាជិក |
| ១៤- | ប្រធានមន្ទីរធនធានទឹក និងឧតុនិយម | សមាជិក |
| ១៥- | ប្រធានមន្ទីរទេសចរណ៍ | សមាជិក |
| ១៦- | ប្រធានមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ១៧- | ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៨- | តំណាងសាខាគយ និងរដ្ឋាកររាជធានី ខេត្ត | សមាជិក |
| ១៩- | តំណាងទីចាត់ការពន្ធដាររាជធានី ឬ តំណាងសាខាពន្ធដារខេត្ត | សមាជិក |
| ២០- | នាយកទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត | លេខាធិការ។ |

សមាសភាពជាក់ស្តែង ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋបាលរាជធានី ខេត្ត។

## ជំពូកទី៣
## តួនាទី និងភារកិច្ច

**មាត្រា៣.-**

**អ.គ.វ.វ.ខ.** មានតួនាទី និងភារកិច្ចពិនិត្យ និងសម្រេចលើការចុះបញ្ជី ការផ្តល់ការលើកទឹកចិត្ត ការធានា ការទិញ ការលក់ ការរួមបញ្ចូលគ្នា ការលុប និងការដោះស្រាយវិវាទនានាពាក់ព័ន្ធនឹងគម្រោងវិនិយោគឯកជន

ដែលមានទុនវិនិយោគសមមូលនឹង៥ (ប្រាំ) លានដុល្លារអាម៉េរិកចុះ នៅក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលរាជធានី ខេត្ត សាមីនីមួយៗ ស្របតាមនីតិវិធីដែលកំណត់ដោយអនុក្រឹត្យដោយឡែក និងស្របតាមបទប្បញ្ញត្តិនានានៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី៤
## កិច្ចដំណើរការការងារ

**មាត្រា៤.-**

សមាសភាពដែលមានចែងក្នុងមាត្រា ២ ខាងលើ ត្រូវអញ្ជើញចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធាន ក្នុងករណីប្រធានអវត្តមាន។

ករណីដែលប្រធានអវត្តមាន **អ.គ.វ.រ.ខ.** អាចដំណើរការប្រជុំក្រោមអធិបតីភាពរបស់អនុប្រធាន តាមការប្រគល់សិទ្ធិរបស់ប្រធាន។

**មាត្រា៥.-**

**អ.គ.វ.រ.ខ.** អាចអញ្ជើញតំណាង ឬមន្ត្រីជំនាញពីក្រសួង ស្ថាប័ន មន្ទីរ អង្គភាពពាក់ព័ន្ធ អភិបាលរងនៃគណៈអភិបាលរាជធានី ខេត្ត និងតំណាងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ពាក់ព័ន្ធ ដែលមិនមែនជាសមាជិក **អ.គ.វ.រ.ខ.** ចូលរួមក្នុងកិច្ចប្រជុំ តាមការចាំបាច់។

**មាត្រា៦.-**

ទីចាត់ការផែនការ និងវិនិយោគនៃរដ្ឋបាលរាជធានី ខេត្ត ត្រូវបំពេញតួនាទីជាលេខាធិការដ្ឋាន សម្រាប់ដោះស្រាយការងារប្រចាំថ្ងៃរបស់ **អ.គ.វ.រ.ខ.**។

**អ.គ.វ.រ.ខ.** ត្រូវប្រើប្រាស់អង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ជាច្រកសម្រាប់ការទទួល និងការផ្តល់សេវារដ្ឋបាលជូនវិនិយោគិនក្នុងការពិនិត្យ និងសម្រេចលើការវិនិយោគ និងការដោះស្រាយវិវាទវិនិយោគ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលរាជធានី ខេត្ត។

**មាត្រា៧.-**

**អ.គ.វ.រ.ខ.** មានសិទ្ធិប្រើប្រាស់ត្រារបស់រដ្ឋបាលរាជធានី ខេត្តសាមីសម្រាប់កិច្ចដំណើរការការងាររបស់ខ្លួន។

**មាត្រា៨.-**

**អ.គ.វ.រ.ខ.** ត្រូវធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ផ្តល់ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា ដើម្បីធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល។

**អ.គ.វ.រ.ខ.** ត្រូវធ្វើសេចក្តីរាយការណ៍ជាទៀងទាត់ជូនក្រុមប្រឹក្សារាជធានី ខេត្ត របស់ខ្លួនក្នុងការអនុវត្តការងារវិនិយោគ។

## ជំពូកទី៥
## ប្រតិភូកម្មសិទ្ធិអំណាច

**មាត្រា៩.-**

គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវធ្វើប្រតិភូកម្មសិទ្ធិអំណាចជូនមន្ទីរ អង្គភាពខ្សែបណ្តោយរបស់ក្រសួង ស្ថាប័ននៅថ្នាក់រាជធានី ខេត្ត ឬរដ្ឋបាលរាជធានី ខេត្ត ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន

ដើម្បីសម្រេចលើកិច្ចការពាក់ព័ន្ធដល់ការចេញលិខិតអនុញ្ញាត អាជ្ញាបណ្ណនានា ក្នុងការចុះបញ្ជីគម្រោងវិនិយោគ ការផ្តល់ការលើកទឹកចិត្ត ការធានា ការទិញ ការលក់ ការរួមបញ្ចូលគ្នា ការលុបគម្រោង និងការដោះស្រាយវិវាទវិនិយោគដែលមានទុនវិនិយោគសមមូលនឹង ៥ (ប្រាំ) លានដុល្លារអាម៉េរិកចុះ។

គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវប្រូសរាន់ចេញបទប្បញ្ញត្តិស្តីពីការណែនាំអនុវត្តជាក់ស្តែង និងធ្វើការបណ្តុះបណ្តាលមុខជំនាញដល់គ្រប់មន្ទីរ អង្គភាពខ្សែបណ្តោយរបស់ខ្លួនក្នុងរាជធានី ខេត្ត ជាសមាជិកនៃ **អ.គ.វ.រ.ខ.** តាមសមត្ថកិច្ចរៀងៗខ្លួន ដើម្បីធានាឱ្យដំណើរការនៃយន្តការនេះប្រព្រឹត្តទៅមានភាពរលូន និងមានប្រសិទ្ធភាពខ្ពស់។

**អ.គ.វ.រ.ខ.** ត្រូវចាប់ផ្តើមអនុវត្តការងាររបស់ខ្លួន បន្ទាប់ពីគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធបានធ្វើប្រតិភូកម្មសិទ្ធិអំណាចជូនគ្រប់មន្ទីរ អង្គភាពខ្សែបណ្តោយរបស់ខ្លួន ដូចមានចែងក្នុងមាត្រានេះ។ ការធ្វើប្រតិភូកម្មសិទ្ធិអំណាចនេះត្រូវធ្វើក្នុងរយៈពេលមិនលើសពី ៣០(សាមសិប) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីរដ្ឋបាលរាជធានី ខេត្ត ចេញសេចក្តីសម្រេចកំណត់ពីសមាសភាពជាក់ស្តែងនៃ **អ.គ.វ.រ.ខ.**។

## ជំពូកទី៦

## គម្រោងវិនិយោគដែលមិនត្រូវឆ្លងយន្តការ អ.គ.វ.រ.ខ.

**មាត្រា១០.-**

គម្រោងវិនិយោគដូចខាងក្រោម មិនឆ្លងការពិនិត្យសម្រេចក្នុងការចុះបញ្ជីគម្រោងវិនិយោគ ការផ្តល់ការលើកទឹកចិត្ត និងការធានាលើការវិនិយោគរបស់ **អ.គ.វ.រ.ខ.** ទេ ដោយត្រូវឆ្លងតាមយន្តការរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា៖

១- គម្រោងវិនិយោគដែលមានទុនវិនិយោគចាប់ពី ៥ (ប្រាំ) លានដុល្លារអាម៉េរិកឡើងទៅ។

២- គម្រោងវិនិយោគដែលមានទីតាំងស្ថិតក្នុងដែនសមត្ថកិច្ចរបស់រាជធានី ខេត្ត ចាប់ពី២(ពីរ) ឡើងទៅ។

៣- គម្រោងវិនិយោគដែលស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស។

៤- គម្រោងវិនិយោគស្ថិតក្រោមច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋ និងឯកជន។

៥- គម្រោងវិនិយោគដែលមានវេទយិតភាពខាងនយោបាយ ឬអាចបង្កគ្រោះថ្នាក់ដល់បរិស្ថាន ឬប៉ះពាល់ដល់សន្តិសុខជាតិ ឬប៉ះពាល់ដល់ការងារអភិរក្ស និងការពារជីវៈចម្រុះ ធនធានធម្មជាតិ និងសម្បត្តិវប្បធម៌ជាតិ។

៦- គម្រោងវិនិយោគពាក់ព័ន្ធនឹងការរុករក និងការធ្វើអាជីវកម្មរ៉ែ និងធនធានធម្មជាតិ។

៧- គម្រោងវិនិយោគពាក់ព័ន្ធនឹងវិស័យថាមពល។

៨- គម្រោងវិនិយោគដែលស្ថិតនៅក្នុងបញ្ជីអវិជ្ជមានដែលនៅជាធរមាន។

មុខងារក្នុងការផ្តល់សេវារដ្ឋបាលពាក់ព័ន្ធនឹងការចុះបញ្ជីការធ្វើអាជីវកម្មរ៉ែ និងថាមពលដែលបានធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបន្តអនុវត្តតាមស្មារតីនៃអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ជំពូកទី៧
## អន្តរប្បញ្ញត្តិ

**មាត្រា១១.-**

គម្រោងវិនិយោគទាំងឡាយ ដែលត្រូវបានចុះបញ្ជី និងទទួលបានការលើកទឹកចិត្តដោយអនុលោមតាមច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ៥ ខែសីហា ឆ្នាំ១៩៩៤, ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ និងអនុក្រឹត្យពាក់ព័ន្ធនានា ត្រូវបន្តឋានៈជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នៅក្រោយអនុក្រឹត្យនេះចូលជាធរមាន។

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**មាត្រា១២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងសមាសភាពដូចមានចែងក្នុងមាត្រា២ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៦កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២ ខែកញ្ញា ឆ្នាំ ២០២២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ